**<u>អត្ថបទបកប្រែក្រៅផ្លូវការ</u>**

**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី, ទីស្តីការគណៈរដ្ឋមន្ត្រី
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លិខិតលេខ RDAP/CB/42/2023
ទីក្រុងម៉ាឌ្រីដ, ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

**សម្តេច ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត** !

ខ្ញុំសូមអនុញ្ញាតសំដែងនូវការថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេច** និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការទទួលបដិសណ្ឋារកិច្ចដ៏វិសេសវិសាលចំពោះរូបខ្ញុំក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំមកកាន់រាជធានីភ្នំពេញ នាឱកាសនៃកិច្ចប្រជុំគណៈកម្មការតំបន់របស់អង្គការទេសចរណ៍ពិភពលោក (UNWTO) និងព្រឹត្តិការណ៍ផ្សេងទៀតដែលបានរៀបចំកាលពីសប្តាហ៍កន្លងមក រួមទាំងសន្និសីទអន្តរជាតិនៃអង្គការទេសចរណ៍ពិភពលោកស្តីពីក្រមអន្តរជាតិសម្រាប់ការការពារភ្ញៀវទេសចរ និងកិច្ចពិភាក្សាតុមូលរបស់សមាជិកបុត្រសម្ព័ន្ធ។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានជួបសំដែងការគួរសមជាមួយ **សម្តេច** នៅវិមានសន្តិភាព ដើម្បីពិភាក្សាអំពីបញ្ហាយុទ្ធសាស្ត្រដែលមានផលប្រយោជន៍រួម ដូចជាការងើបឡើងវិញនៃឧស្សាហកម្មទេសចរណ៍ដែលរងផលប៉ះពាល់ពីជំងឺរាតត្បាតសកល និងសារៈសំខាន់នៃក្រមអន្តរជាតិសម្រាប់ការការពារភ្ញៀវទេសចរ។

ការប្តេជ្ញាចិត្ត និងការប្រកាន់ខ្ជាប់របស់កម្ពុជាចំពោះក្រមអន្តរជាតិសម្រាប់ការការពារភ្ញៀវទេសចរ ព្រមជាមួយឆន្ទៈរបស់ប្រទេស **សម្តេច** ក្នុងការដឹកនាំការអនុម័តសេចក្តីប្រកាសភ្នំពេញស្តីពីក្រមអន្តរជាតិនេះទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក គឺពិតជាគួរឱ្យស្ងើចសរសើរ។ ប្រទេសរបស់ **សម្តេច** ពិតជានឹងធ្វើក្លាយជាគំរូក្នុងតំបន់ និងលើសពីនេះ ហើយនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជួយភ្ញៀវទេសចរក្នុងស្ថានភាពអាសន្ន ព្រមជាមួយការជំរុញកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើងទាំងអស់គ្នា ឆ្ពោះទៅរកការលើកកម្ពស់ទំនុកចិត្តរបស់អ្នកប្រើប្រាស់នៅក្នុងវិស័យទេសចរណ៍។

ខ្ញុំសូមអនុញ្ញាតឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់ឡើងវិញនូវការអញ្ជើញរបស់ខ្ញុំជូនចំពោះ **សម្តេច** ដើម្បីចូលរួមមហាសន្និបាតលើកទី២៥ របស់អង្គការទេសចរណ៍ពិភពលោក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងសាម៉ាកាន (Samarkand) ប្រទេសយូបេគីស្ថាន (Uzbekistan) ចាប់ពីថ្ងៃទី១៦-២០ ខែតុលា ឆ្នាំ២០២៣។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ការចូលរួមរបស់ **សម្តេច** នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ការអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា។

ខ្ញុំពិតជាទន្ទឹងរង់ចាំជួប **សម្តេច** នៅទីក្រុងសាម៉ាកាន (Samarkand) និងរំពឹងទទួលបាននូវកិច្ចសហការប្រកបដោយផ្លែផ្ការរបស់យើងនៅបណ្តាឆ្នាំខាងមុខ។

សូម **សម្តេច** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

(ហត្ថលេខា)

**ហ្សូរាប ប៉ូលូលីកាសវីលី**
**អគ្គលេខាធិការអង្គការទេសចរណ៍ពិភពលោក**